ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តកណ្តាល

**សំណុំរឿងរដ្ឋប្បវេណី**
លេខ ៧០៦
ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩
**សាលក្រមរដ្ឋប្បវេណី**
លេខ ៥៧ "ផ"
ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ។

**ចៅក្រម**

លោក **គីម រ័ត្នណារិន** ចៅក្រមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជី**

លោកស្រី **ស៊ុំ គន្ធា** ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**-ដើមចោទ៖** ធនាគារ **ជ** អាសយដ្ឋាន រាជធានីភ្នំពេញ ។

ដោយមានលោក សួន ប៊ុនធឿន និងលោក ជា បុរមុនី ជាមេធាវីតំណាងដោយអាណត្តិ ។

**-សហចុងចម្លើយ៖**

១-ឈ្មោះ **ច១** ភេទប្រុស កើតឆ្នាំ១៩៧៩ អាសយដ្ឋាន ខេត្តកណ្តាល ។

២-ឈ្មោះ **ច២** ភេទស្រី កើតឆ្នាំ១៩៦៥ អាសយដ្ឋាន ខេត្តកណ្តាល ។

៣-ឈ្មោះ **ច៣** ភេទស្រី កើតឆ្នាំ១៩៨១ អាសយដ្ឋាន ខេត្តកណ្តាល ។

## អង្គហេតុ និងចំណុចវិវាទ

**ក-ការទាមទាររបស់ដើមចោទ៖** ប្តឹងសុំឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារបង្គាប់ឲ្យសហចុងចម្លើយ រួមគ្នាសងមកឲ្យដើមចោទនូវ៖

១.បំណុលប្រាក់ដើមសរុបចំនួន USD ៣៤.៤៥០,០៥ (សាមសិបបួនពាន់មួយរយហាសិបដុល្លារអាមេរិក ក្បៀសសូន្យប្រាំសេន) ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

២.ការប្រាក់គិតចាប់ពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ ក្នុងអត្រាការប្រាក់ ១២% ក្នុងមួយឆ្នាំលើប្រាក់ដើម USD ៣៤.៤៥០,០៥ (សាមសិបបួនពាន់មួយរយហាសិបដុល្លារអាមេរិក កៀសសូន្យប្រាំសេន) ។

៣.ការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ ក្នុងអត្រាស្មើនឹង ២ដងនៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់លេខ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៨ ។

៤.សេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្តចំនួន USD ៥.០០០ (ប្រាំពាន់ដុល្លារអាមេរិក) ។

៥.ប្រាក់ប្រដាប់ក្តី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់ចុងចម្លើយ ។

៦.សាលក្រមនេះអាចអនុវត្តបណ្តោះអាសន្នបានត្រង់ចំណុចទី១, ២ និង ៣ ខាងលើ ។

ខ-ការពន្យល់ត្រួសៗអំពីរឿងក្តី ៖

យោងតាមពាក្យបណ្តឹង ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ របស់ឈ្មោះ ធនាគារ ដ បានអះអាងថា កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ បានចុះកិច្ចសន្យាខ្ចីប្រាក់ពី ធនាគារ ដ ដែលមានទឹកប្រាក់សរុបចំនួន USD ៣៥.០០០ (សាមសិបប្រាំពាន់ដុល្លារអាមេរិក) តាមអត្រាការប្រាក់ ១២%ក្នុងមួយឆ្នាំ រយៈពេលខ្ចីប្រាក់ ៧២ខែ ដោយធ្វើការរំលស់ប្រាក់ដើម និងការប្រាក់រៀងរាល់ខែ គិតចាប់ពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ដល់ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៤ និងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៤ សងផ្តាច់ប្រាក់ដើមដែលនៅសល់ និងការប្រាក់ជាក់ស្តែង ។ របៀបនៃការសងប្រាក់ត្រូវអនុវត្តតាមតារាងកាលវិភាគសងប្រាក់របស់ធនាគារ ដោយការសងប្រាក់ដើម និងការប្រាក់មួយលើកៗត្រូវបង់ប្រាក់ផ្ទាល់ ឬកាត់យកជាស្វ័យប្រវត្តិពីគណនីរបស់សហចុងចម្លើយដូចមានក្នុងចំណុច៥ ប្រការ១.២ នៃកិច្ចសន្យាខ្ចីប្រាក់លេខ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ។ ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន សហចុងចម្លើយមិនបានគោរពកាតព្វកិច្ចនៃការបង់ប្រាក់តាមកិច្ចសន្យាឡើយ ដោយបានខកខានបង់ប្រាក់ដើម និងការប្រាក់ជូនធនាគារអស់ជាច្រើនខែ ទោះបីជាធនាគារបានធ្វើការក្រើនរំលឹកជាច្រើនលើកច្រើនសារក៏ដោយ ក៏ចុងចម្លើយមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនឡើយ ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

គ.ការអះអាងរបស់គូភាគី ៖

-លោក ជា បុរមុនី មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ធ ថ្លែងការណ៍ថា: សុំរក្សាពាក្យបណ្តឹង ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ និងសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ ទុកជាបានការដដែល ដោយហេតុថា កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ចុងចម្លើយបានខ្ចីប្រាក់ពីធនាគារចំនួន ៣៥.០០០ ដុល្លារអាមេរិក តាមអត្រា ១២%ក្នុងមួយឆ្នាំ មានរយ:ពេលខ្ចី ៧២ខែ និងធ្វើការរំលស់ជារៀងរាល់ខែ ចំនួន ៦៨៨ ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ដល់ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៤ និងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៤ ត្រូវសងផ្តាច់នូវប្រាក់ដែលនៅសល់ ។ ក្នុងការអនុវត្តកាតព្វកិច្ច ចុងចម្លើយបានខកខានសងប្រាក់មកធនាគារ គិតចាប់ពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្ន ទោះបីធនាគារព្យាយាមសម្របសម្រួល ក៏ចុងចម្លើយនៅតែមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែលដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍កូនក្តីខ្លួនយ៉ាងធ្ងន់ធ្ងរ ។ សំណូមពរ សុំឲ្យតុលាការសម្រេចតាមការស្នើសុំ ។

-ចុងចម្លើយឈ្មោះ ចា និងឈ្មោះ ច២ ថ្លែងការណ៍តបថា៖ ខ្លួនទទួលស្គាល់ប្រាក់ដែលខ្លួនបានខ្ចីពីធនាគារគឺមានចំនួន ៣៥.០០០ ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ១២%ក្នុងមួយឆ្នាំ ។ ក្រោយមក ខ្លួនបានខកខានបង់ឲ្យធនាគារពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ ដោយហេតុថា ខ្លួនអត់មានលទ្ធភាពបង់ ។ ខ្លួននៅជំពាក់ប្រាក់ដើមធនាគារចំនួន ៣៤.៤៥០,០៥ (សាមសិបបួនពាន់បួនរយហាសិបដុល្លារអាមេរិក និងប្រាំសេន) ។ ចំពោះអត្រាការប្រាក់ ១២%ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៨ ដល់ថ្ងៃសងខ្លួនឯកភាពសង ប៉ុន្តែខ្លួនសុំឲ្យខាងធនាគារអនុគ្រោះចំពោះប្រាក់ពិន័យ សេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងជម្ងឺចិត្ត ៥.០០០ដុល្លារអាមេរិក ព្រមទាំងប្រាក់ប្រដាប់ក្តីនិងការចំណាយលើនីតិវិធីតុលាការ ។ ចំពោះការស្នើសុំឲ្យអនុវត្តជាបណ្តោះអាសន្ន ខ្លួនមិនឯកភាពទេ ។ ខ្លួនសុំសងប្រាក់ដើមដែលខ្លួននៅជំពាក់ធនាគារចំនួន ៣៤.៤៥០,០៥ (សាមសិបបួនពាន់បួនរយហាសិបដុល្លារអាមេរិក និងប្រាំសេន) ខ្លួនសុំបង់រំលស់ចំនួន ៤០០ ដុល្លារអាមេរិក ក្នុងមួយខែរហូតដល់សងគ្រប់ ។

ឃ.ចំណុចវិវាទ៖

-ដើមចោទសុំឲ្យចុងចម្លើយសងប្រាក់ដើមចំនួន ៣៤.៤៥០,០៥ (សាមសិបបួនពាន់បួនរយហាសិបដុល្លារអាមេរិក និងប្រាំសេន) ក្នុងអត្រា ១២% ក្នុងមួយឆ្នាំ តែចុងចម្លើយសុំសងរំលស់ចំនួន ៤០០ ដុល្លារអាមេរិក ក្នុងមួយខែ ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

-ដើមចោទសុំឱ្យចុងចម្លើយសងប្រាក់ពិន័យ សេវាផ្នែកច្បាប់ និងប្រាក់ប្រដាប់ក្តីតុលាការ តែចុងចម្លើយសុំឱ្យដើមចោទអនុគ្រោះ ។

-ដើមចោទស្នើសុំអនុវត្តបណ្តោះអាសន្នលើប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យ តែចុងចម្លើយមិនឯកភាព ។

**ឯកសារភស្តុតាងមាន៖**

+កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ រវាង **ធនាគារ** ជ និងឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ ។

+កិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ រវាង **ធនាគារ** ជ និងឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរ និងពិនិត្យភស្តុតាងក្នុងពេលទាញហេតុផលដោយផ្ទាល់មាត់ឃើញថា ៖

-ពាក្យបណ្តឹង ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ របស់ដើមចោទ **ធនាគារ** ជ មានលក្ខណៈត្រឹមត្រូវ បញ្ជាក់ឱ្យឃើញថា សាលាដំបូងខេត្តកណ្តាលមានដែនសមត្ថកិច្ច ដើម្បីវិនិច្ឆ័យស្របច្បាប់នូវពាក្យបណ្តឹង ហើយចេញសាលក្រមបានតាមមាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-លោក **ជា បុរមុនី** មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ **ធនាគារ** ជ ថ្លែងការណ៍ថា កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ចុងចម្លើយបានខ្ចីប្រាក់ពីធនាគារចំនួន ៣៥.០០០ ដុល្លារអាមេរិក តាមអត្រា ១២%ក្នុងមួយឆ្នាំ មានរយៈពេលខ្ចី ៧២ខែ និងធ្វើការរំលស់ជារៀងរាល់ខែ ចំនួន ៦៨៨ ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ដល់ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៤ និងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៤ ត្រូវសងផ្តាច់នូវប្រាក់ដែលនៅសល់ ។ ក្នុងការអនុវត្តកាតព្វកិច្ច ចុងចម្លើយបានខកខានសងប្រាក់មកធនាគារ គិតចាប់ពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្ន ទោះបីធនាគារព្យាយាមសម្របសម្រួលក៏ចុងចម្លើយនៅតែមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនដដែល ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍កូនក្តីខ្លួនយ៉ាងធ្ងន់ធ្ងរ ។ សំណូមពរ សុំឱ្យតុលាការសម្រេចតាមការស្នើសុំ ។

-សហចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ ត្រូវបានតុលាការកោះហៅតាមដីកាកោះ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ រួចហើយ តែចុងចម្លើយបានអវត្តមាននាពេលទាញហេតុផលដោយផ្ទាល់មាត់ដោយគ្មានមូលហេតុ ហេតុនេះតុលាការចាត់ទុកថាចុងចម្លើយបានសារភាព តាមសេចក្តីថ្លែង

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

ការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុខាងលើ ហើយតុលាការអាចចេញសាលក្រមកំបាំងមុខបាន យោងតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-ចុងចម្លើយឈ្មោះ ច៣ និងឈ្មោះ ច២ បានថ្លែងការណ៍នាទីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា ខ្លួនទទួលស្គាល់ប្រាក់ដែលខ្លួនបានខ្ចីពីធនាគារគឺមានចំនួន ៣៥.០០០ ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ១២%ក្នុងមួយឆ្នាំ ។ ក្រោយមក ខ្លួនបានខកខានបង់ឱ្យធនាគារពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ ដោយហេតុថា ខ្លួនអត់មានលទ្ធភាពបង់ ។ ខ្លួននៅជំពាក់ប្រាក់ដើមធនាគារចំនួន ៣៤.៤៥០,០៥ (សាមសិបបួនពាន់បួនរយហាសិបដុល្លារអាមេរិក និងប្រាំសេន) ។ ចំពោះអត្រាការប្រាក់ ១២%ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៨ ដល់ថ្ងៃសង ខ្លួនឯកភាពសង ប៉ុន្តែខ្លួនសុំឱ្យខាងធនាគារអនុគ្រោះចំពោះប្រាក់ពិន័យ សេវាកម្មច្បាប់ ការខាតបង់ពេលវេលានិងជម្ងឺចិត្ត ៥.០០០ដុល្លារអាមេរិក ព្រមទាំងប្រាក់ប្រដាប់ក្តីនិងការចំណាយលើនីតិវិធីតុលាការ ។ ចំពោះការស្នើសុំឱ្យអនុវត្តជាបណ្តោះអាសន្ន ខ្លួនមិនឯកភាពទេ ។ ខ្លួនសុំសងប្រាក់ដើមដែលខ្លួននៅជំពាក់ធនាគារចំនួន ៣៤.៤៥០,០៥ (សាមសិបបួនពាន់បួនរយហាសិបដុល្លារអាមេរិក និងប្រាំសេន) ខ្លួនសុំបង់រំលស់ចំនួន ៤០០ ដុល្លារអាមេរិក ក្នុងមួយខែរហូតដល់សងគ្រប់ ។

-តាមភស្តុតាងជាឯកសារ កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ និងកិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ រវាង ធនាគារ ធ និងឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ បញ្ជាក់ថា ចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ ពិតជាបានខ្ចីប្រាក់ពី ធនាគារ ធ ចំនួន USD ៣៥.០០០ (សាមសិបប្រាំពាន់ដុល្លារអាមេរិក) តាមអត្រាការប្រាក់ ១២%ក្នុងមួយឆ្នាំ រយៈពេលខ្ចី ៧២ខែ ប្រាដកមែន ដោយបានដាក់បញ្ចាំនូវអចលនវត្ថុចំនួន ០១កន្លែងដែលមានទំហំ ១២៤.១៦ម² មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្ថិតនៅ ខេត្តកណ្តាល ដើម្បីធានាបំណុល ។

-តុលាការយល់ឃើញថា ចុងចម្លើយបានថ្លែងការណ៍ទទួលស្គាល់ថា ពិតជានៅបានជំពាក់ប្រាក់ធនាគារ ធ ចំនួន ៣៤.៤៥០,០៥ (សាមសិបបួនពាន់បួនរយហាសិបដុល្លារអាមេរិក និងប្រាំសេន) និងបានខកខានក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនចំពោះខាងធនាគារ ប្រាកដមែន ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

-គូភាគីបានព្រមព្រៀងគ្នាក្នុងអត្រាការប្រាក់ ១២% ក្នុងមួយឆ្នាំ ដែលអត្រាការប្រាក់នេះគឺស្របតាមអត្រាការប្រាក់ដែលត្រូវបានកម្រិតតាមមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី និងប្រកាសលេខ ១០៨ ក.យ/ប្រ.ក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ ហេតុនេះគប្បីតុលាការពិចារណា ។

-ដើមចោទបានទាមទារការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ ក្នុងអត្រាស្មើនឹង ០២(ពីរ)ដង នៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់លេខ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ។ តុលាការយល់ឃើញថា ការទាមទារនេះគឺមានលក្ខណៈត្រឹមត្រូវ ដោយហេតុថា យោងតាមប្រការ ២.២ នៃកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ គឺគូភាគីពិតជាបានព្រមព្រៀងគ្នាថា បើចុងចម្លើយមិនបានបង់ប្រាក់ទាន់ពេលវេលាតាមតារាងកាលវិភាគសងប្រាក់នៃកិច្ចសន្យា ចុងចម្លើយត្រូវបង់ប្រាក់ពិន័យ ស្មើនឹង ០២ដង នៃអត្រាការប្រាក់ក្នុងកិច្ចសន្យារហូតដល់ការប្រាក់ជំពាក់ត្រូវបានសងបញ្ចប់ ប្រាកដមែន គប្បីតុលាការពិចារណា ។

-ដើមចោទទាមទារឲ្យចុងចម្លើយសងថ្លៃសេវាច្បាប់ ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្តចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក គប្បីតុលាការពិនិត្យ និងសម្រេចតាមភាពសមរម្យជាក់ស្តែង ។

-ដើមចោទសុំអនុវត្តបណ្តោះអាសន្នត្រង់ចំណុចទី១ ប្រាក់ដើម ចំណុចទី ២ ការប្រាក់ និងទី៣ ប្រាក់ពិន័យ ឃើញថាមានលក្ខណៈត្រឹមត្រូវ ដោយហេតុថាចុងចម្លើយបានទទួលស្គាល់បំណុល មានភស្តុតាងច្បាស់លាស់ ហើយការសម្រេចនេះជាការសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ ដែលអាចឲ្យតុលាការធ្វើការសម្រេចប្រកាសសាលក្រមមានអានុភាពអនុវត្តបណ្តោះអាសន្ន តាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-ប្រាក់ប្រដាប់ក្តីយោងតាមបញ្ញតិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីជាបន្ទុករបស់សហចុងចម្លើយ ។

## សេចក្តីសម្រេចបញ្ចប់

១-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ ប១ ឈ្មោះ ប២ និងឈ្មោះ ប៣ រួមគ្នាសងប្រាក់ដើមចំនួន USD ៣៤.៤៥០,០៥ (សាមសិបបួនពាន់មួយរយហាសិបដុល្លារអាមេរិក កៀសសូន្យប្រាំសេន) ទៅឲ្យដើមចោទ ធនាគារ ជ តំណាងស្របច្បាប់ដោយលោក ត១ជ លោក ត២ជ និងលោក ត៣ជ ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្ដីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

២-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ រួមគ្នាសងការប្រាក់គិតចាប់ពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ ក្នុងអត្រាការប្រាក់ ១២% ក្នុងមួយឆ្នាំលើប្រាក់ដើម USD ៣៤.៤៥០,០៥ (សាមសិបបួនពាន់មួយរយហាសិបដុល្លារអាមេរិក ក្បៀសសូន្យប្រាំសេន)ទៅឲ្យដើមចោទ ធនាគារ ដ តំណាងស្របច្បាប់ដោយលោក ត១ដ លោក ត២ដ និងលោក ត៣ដ ។

៣-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ រួមគ្នាសងការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ ក្នុងអត្រាស្មើនឹង ០២ (ពីរ) ដង នៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់លេខ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ទៅឲ្យដើមចោទ ធនាគារ ដ តំណាងស្របច្បាប់ដោយលោក ត១ដ លោក ត២ដ និងលោក ត៣ដ ។

៤-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ រួមគ្នាបង់សេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្តចំនួន ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ទៅឲ្យដើមចោទ ធនាគារ ដ តំណាងស្របច្បាប់ដោយលោក ត១ដ លោក ត២ដ និងលោក ត៣ដ ។

៥-សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបានត្រង់ចំណុច ទី១ ទី២ និងទី៣ នៃសេចក្ដីសម្រេចបញ្ចប់ខាងលើ ។

៦-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ ។

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

**ចៅក្រម**

ហត្ថលេខា និងត្រា គឹម វឌ្ឍណារិន

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កណ្ដាល,ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩

**បានឃើញ**

**ចៅក្រម**

**ក្រឡាបញ្ជី**